លេខ / N°: D128.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

## សម្ងាត់-ខ្ទបសម្ពន្ធ

## ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង មាស មុត

**បានឃើញ** *ដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ* ដាក់នៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥[1]។

**បានឃើញ** ថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញាទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា(“ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ”)[2] និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣ (“ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម”)[3] ចោទប្រកាន់ថា **មាស មុត** ទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក។

**បានឃើញថា** ការចោទប្រកាន់ទាំងនេះត្រូវបានសហព្រះរាជអាជ្ញាអន្តរជាតិកំណត់លក្ខណៈផ្លូវច្បាប់ដូចជាងក្រោម៖

- **ការរំលោភបំពានមាត្រា ៥០០, ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧ និង ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦** ( ទារុណកម្ម និងមនុស្សឃាត)

---

[1] សំណុំរឿង០០៣ ឯកសារ D128 *ដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ* ថ្ងៃទី *៣* ខែ *មីនា* ឆ្នាំ ២០១៥។

[2] សំណុំរឿង ០០៣ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨។ សំណុំរឿង ០០៣ ឯកសារ D1/1 *ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ២ របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី* ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ២០០៩ ។

[3] សំណុំរឿង ០០៣ ឯកសារ D120 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣* ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរសព្ទលេខ +៨៥៥(០)២៣ ២១៩៨១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៩៨៤១។

- **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**(ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងទៀត) និង
- **អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩**(ការធ្វើមនុស្សឃាតដោយចេតនា ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព និងការធ្វើទារុណកម្ម)។

**បានឃើញ**ថា បទល្មើសទាំងនេះមានចែងនៅក្នុងមាត្រា ៣ ថ្មី, ៥ និង ៦ និងត្រូវផ្តន្ទាទោសតាមមាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

**បានឃើញ**ករណីខ្វែងយោបល់គ្នាបានចុះបញ្ជីនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤[4]។

អាស្រ័យហេតុនេះ យើង **Mark B. HARMON** សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា **ដាក់ឲ្យស្ថិតក្រោមការពិនិត្យ៖**

១. **មាស មុត** កើតនៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៣៨ នៅភូមិពោធិ៍ ឃុំស្រែក្នុង ស្រុកឈូក ខេត្តកំពត ប្រទេសកម្ពុជា និងមានទីលំនៅ[redacted] ពីបទឧក្រិដ្ឋដែលនៅស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក។

២. **មាស មុត** គឺជាលេខាកងពលធំលេខ ៣/កងពលធំលេខ ១៦៤ នៃកងទ័ពបដិវត្តកម្ពុជា ("ក.ប.ក") ជាមេបញ្ជាការនៃកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ និងជាលេខាក្រុងកំពង់សោម នៅក្នុងដែនដីកម្ពុជា នៅក្នុងរយៈកាលពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៧៩ និងជាតំណាង សេនាធិការកងទ័ពនៅខេត្តក្រចេះ យ៉ាងហោចណាស់ពីថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៩៧៨ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។ នៅក្នុង រយៈកាលនេះ **មាស មុត** បានប្រើប្រាស់សិទ្ធិអំណាច និងការគ្រប់គ្រងដ៏មានប្រសិទ្ធភាពនៅ

[4]កំណត់ហេតុនៃករណីខ្វែងយោបល់គ្នា ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤។

កំពង់សោម (រាប់បញ្ចូលទាំង ដែនទឹក និងកោះ ដែលកម្ពុជាប្រជាធិបតេយ្យ បានអះអាងថាជាអធិបតេយ្យភាពរបស់ខ្លួន) និងកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ (តាមរយៈកងពលធំលេខ ៣/កងពលធំលេខ ១៦៤នៃកងទ័ពបដិវត្តកម្ពុជា) ព្រមទាំងប្រើប្រាស់សិទ្ធិអំណាច និងការគ្រប់គ្រងដ៏មានប្រសិទ្ធភាពទៅលើអង្គភាពក្រោមបង្គាប់ និងក្រោមចំណុះទាំងអស់ដែលស្ថិតនៅក្នុងតំបន់ទទួលខុសត្រូវរបស់គាត់។

<u>ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦</u>

៣. **មាស មុត** ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទមនុស្សឃាតដោយរំលោភបំពានមាត្រា ៥០១ និង ៥០៦នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ទាក់ទងនឹង៖

- ក) ការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខ វត្តឥន្ទញាណ
- ខ) "ការបោសសម្អាត"ជនដែលត្រូវបានចាត់ទុកថាជាខ្មាំង និងជនក្បត់នៅកំពង់សោម ដោយអ្នកខ្លះត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ (ភ្នំពេញ)
- គ) "ការបោសសម្អាត"កម្មាភិបាលកងពលលេខ ១១៧ និងតំបន់ ៥០៥ នៅខេត្តក្រចេះដែលត្រូវបានចាត់ទុកថាជាខ្មាំង ឬជនក្បត់ ដោយអ្នកខ្លះត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ (ភ្នំពេញ) និង
- ឃ) ការសម្លាប់ជនស៊ីវិលវៀតណាម និងថៃ (អ្នកនេសាទ និងជនភៀសខ្លួន) និងជនបរទេសផ្សេងទៀតនៅដែនសមុទ្រ និងនៅលើកោះដែលកម្ពុជាប្រជាធិបតេយ្យ បានអះអាងថាជាអធិបតេយ្យភាព។

៤. **មាស មុត** ក៏ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋនៃការធ្វើទារុណកម្មដោយរំលោភបំពានមាត្រា ៥០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលមានចែង និងត្រូវផ្តន្ទាទោសតាមត្រា ៣(ថ្មី), ២៩ និង ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ទាក់ទងនឹងមន្ទីរសន្តិសុខវត្តឥន្ទញាណ។

៥. ការរំលោភបំពានក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ មានចែងនៅក្នុងមាត្រា ៣ ថ្មី និងត្រូវផ្តន្ទាទោសតាមមាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

<u>ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ</u>

៦. **មាស មុត** ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យដោយសារឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តជាផ្នែកមួយនៃការវាយប្រហារជាទូទៅ និងជាប្រព័ន្ធមកលើប្រជាជនស៊ីវិល។

៧. **មាស មុត** ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យដោយសារឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍ទៅលើជនជាតិវៀតណាម និងអតីតទាហាន និងអតីតមន្ត្រីសាធារណរដ្ឋខ្មែរ ដែលត្រូវបានចាត់ទុកថាជនក្បត់ ឬខ្មាំង និងអំពើអមនុស្សធម៌ផ្សេងទៀត(ដូចជា ការបាត់ខ្លួនដោយបង្ខំ និង ការវាយប្រហារលើភាពថ្លៃថ្នូររបស់មនុស្សដោយសារការដកហូតមិនឲ្យមានអាហារគ្រប់គ្រាន់)ទាក់ទងនឹង៖

ក) មន្ទីរសន្តិសុខ វត្តឥន្ទញាណ

ខ) "ការបោសសម្អាត"ជនដែលត្រូវបានចាត់ទុកថាជាខ្មាំង និងជនក្បត់នៅកំពង់សោម ដោយអ្នកខ្លះត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ (ភ្នំពេញ)

គ) "ការបោសសម្អាត"កម្មាភិបាលកងពលលេខ ១១៧ និងតំបន់ ៥០៥ នៅខេត្តក្រចេះដែលត្រូវបានចាត់ទុកថាជាខ្មាំង ឬជនក្បត់ ដោយអ្នកខ្លះត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ (ភ្នំពេញ) និង

ឃ) ជនស៊ីវិលវៀតណាម និងថៃ (អ្នកនេសាទ និងជនភៀសខ្លួន) និងជនបរទេសផ្សេងទៀតនៅដែនសមុទ្រ និងនៅលើកោះដែលកម្ពុជាប្រជាធិបតេយ្យ បានអះអាងជាថាអធិបតេយ្យភាព។

៨. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានចែងនៅក្នុងមាត្រា ៥ និងត្រូវផ្តន្ទាទោសតាមមាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

<u>អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ</u>

៩. **មាស មុត** ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យដោយសារការប្រព្រឹត្តអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ នៅក្នុងបរិបទនៃស្ថានភាពជម្លោះប្រដាប់អាវុធអន្តរជាតិចំនួនពីរ៖ (i) រវាងកម្ពុជាប្រជាធិបតេយ្យជាមួយ វៀតណាម (ផ្លាស់ឈ្មោះទៅជា សាធារណរដ្ឋសង្គមនិយមវៀតណាម បន្ទាប់ពីថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ១៩៧៦) គឺសាធារណរដ្ឋសង្គមនិយមវៀតណាម នៅក្នុងរយៈកាលទាំងស្រុង ឬនៅក្នុងរយៈកាលខ្លះរវាងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ និង(ii) រវាងកម្ពុជាប្រជាធិបតេយ្យ ជាមួយថៃ នៅក្នុងរយៈកាលទាំងស្រុង ឬនៅក្នុងរយៈកាលខ្លះរវាងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។

១០. **មាស មុត** ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋនៃការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើបាបដោយអមនុស្សធម៌ ការនិរទេស ឬការផ្លាស់ទីដោយខុសច្បាប់ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព និងការធ្វើទារុណកម្មទាក់ទងនឹង៖

ក) “ការបោសសម្អាត”ជនដែលត្រូវបានចាត់ទុកថាជាខ្មាំង និងជនក្បត់នៅកំពង់សោម ដោយអ្នកខ្លះត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ (ភ្នំពេញ)

ខ) “ការបោសសម្អាត”កម្មាភិបាលកងពលលេខ ១១៧ និងតំបន់ ៥០៥ នៅខេត្តក្រចេះដែលត្រូវបានចាត់ទុកថាជាខ្មាំង ឬជនក្បត់ ដោយអ្នកខ្លះត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ (ភ្នំពេញ) និង

គ) ជនស៊ីវិលវៀតណាម និងថៃ (អ្នកនេសាទ និងជនភៀសខ្លួន) និងជនបរទេសផ្សេងទៀតនៅដែនសមុទ្រ និងនៅលើកោះដែលកម្ពុជាប្រជាធិបតេយ្យ បានអះអាងថាជាអធិបតេយ្យភាពរបស់ខ្លួន។

១១. អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ មានចែងនៅក្នុងមាត្រា ៦ និងត្រូវផ្តន្ទាទោសតាមមាត្រា ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

<u>ទម្រង់នៃការទទួលខុសត្រូវ</u>

១២. **មាស មុត** ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋទាំងនេះតាមរយៈការប្រព្រឹត្តិ (តាមរយៈការប្រព្រឹត្តិបទល្មើសសហចារី)ការរៀបចំផែនការ ការញុះញង់ ការបញ្ជា និងការជួយ និងជំរុញឲ្យមានបទឧក្រិដ្ឋដែលគាត់ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យ។

១៣. **មាស មុត** ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋដូចបានរៀបរាប់នៅក្នុងខណ្ឌ ៦ ដល់ ១១ តាមរយៈការប្រព្រឹត្តិ(តាមរយៈការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួម)ការរៀបចំផែនការ ការញុះញង់ ការបញ្ជា និងការជួយ និងជំរុញឲ្យមានបទឧក្រិដ្ឋដែលគាត់ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យ។

១៤. សហឧក្រិដ្ឋកម្មរួមដែលបានលើកឡើងខាងលើ បានកើតឡើងយ៉ាងហោចណាស់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់យ៉ាងហោចណាស់ថ្ងៃទី៦ ខែ មករា ឆ្នាំ ១៩៧៩ ហើយជនចូលរួមសហឧក្រិដ្ឋកម្មរួមទាំងនេះរួមបញ្ចូល ប៉ុន្តែមិនកំណត់ទេ ដូចជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ សមាជិកគណៈកម្មាធិការមជ្ឈិម លេខាភូមិភាគ លេខាតំបន់ស្វ័យត ប្រធានកងពលកងទ័ពមជ្ឈិមបក្ស សេនាធិការកងទ័ពបដិវត្តកម្ពុជា និងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា("ប.ក.ក")ផ្សេងទៀត ដែលបានចូលរួមគោលបំណងរួមក្នុងការអនុវត្តគោលនយោបាយខាងក្រោមនេះរបស់ ប.ក.ក តាមរយៈការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក៖

ក. ការផ្លាស់ទីប្រជាជនជាបន្តបន្ទាប់ពីតំបន់ប្រជុំជន និងទីក្រុងទៅជនបទ និងពីជនបទ ទៅកន្លែងផ្សេងទៀត

ខ. ការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាន

ខ. ការកសាង"សមាសភាពមិនល្អ" និងការសម្លាប់"ខ្មាំង"ទាំងនៅក្នុង ទាំងនៅក្រៅជួរ ប.ក.ក

គ. ការដាក់មុខសញ្ញាលើក្រុមជាក់លាក់នានា ជាពិសេសជនជាតិវៀតណាម និងអតីតមន្ត្រីសាធារណរដ្ឋខ្មែរ រាប់បញ្ចូលទាំងមន្ត្រីស៊ីវិល ទាំងអតីតទាហាន និងគ្រួសាររបស់ពួកគេ។

ឃ. ការដាក់បទបញ្ជាលើអាពាហ៍ពិពាហ៍

១៥. គោលបំណងនៃគោលនយោបាយរបស់ ប.ក.ក គឺដើម្បីអនុវត្តបដិវត្តន៍សង្គមនិយមឲ្យបានឆាប់រហ័សនៅក្នុងប្រទេសកម្ពុជា តាមរយៈជំហាន"មហាលោតផ្លោះ" និងដើម្បីការពារ ប.ក.ក ប្រឆាំងនឹងខ្មាំងផ្ទៃក្នុង និងខាងក្រៅ តាមមធ្យោបាយអ្វីក៏ដោយដែលចាំបាច់។

១៦. **មាស មុត** ក៏ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋដូចបានរៀបរាប់នៅក្នុងកថាខណ្ឌ ៣ ដល់ ១១ តាមរយៈការទទួលខុសត្រូវថ្នាក់លើ។ ក្នុងនាមជាថ្នាក់លើដែលប្រើប្រាស់ការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើជនក្រោមបង្គាប់ **មាស មុត** បានដឹងឮ ឬបានប្រព្រឹត្តអំពើដែលគាត់ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យ ហើយគាត់ខកខានមិនបានចាត់វិធានការចាំបាច់ និងសមហេតុផលដើម្បីទប់ស្កាត់អំពើបែបនោះ ឬក៏ដាក់ទណ្ឌកម្មជនប្រព្រឹត្ត។

១៧. ទម្រង់នៃការទទួលខុសត្រូវទាំងនេះមានចែងនៅក្នុងមាត្រា ២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

<u>ការជូនដំណឹងបន្ថែមទៀត</u>

១៨. ដោយអនុលោមតាមវិធានផ្ទៃក្នុង ១១,២១, និង២២ និងបទបញ្ជារដ្ឋបាលជាធរមាន **មាស មុត** មានសិទ្ធិមានតំណាងជាមេធាវីតាមការជ្រើសរើសរបស់ខ្លួន។ ត្រង់ចំណុចនេះ ខ្ញុំ កត់សម្គាល់ថា **មាស មុត** បច្ចុប្បន្ននេះមានតំណាងរួចហើយគឺលោក អាង ឧត្តម សហមេធាវីជាតិ និង លោក Michael G. KARNAVAS សហមេធាវីអន្តរជាតិ[5]។

[5]សំណុំរឿង០០៣ ឯកសារD56/19/38 *សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់មាស មុត ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលបដិសេធការតែងតាំងលោកអាង ឧត្តម និងលោក Michael KARNAVAS មិនឲ្យធ្វើជាសហមេធាវីរបស់គាត់* ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤។

១៩. ដោយអនុលោមតាមវិធានផ្ទៃក្នុង ២១(១)(ឃ) **មាស មុត** មានសិទ្ធិនៅស្ងៀមមិនឆ្លើយតប នៅក្នុងអំឡុងពេលស៊ើបសួរ។

២០. ដោយអនុលោមតាមវិធានផ្ទៃក្នុង ៥៨(៦) **មាស មុត** មានសិទ្ធិស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត សួរចម្លើយគាត់នៅគ្រប់ពេលក្នុងអំឡុងពេលស៊ើបសួរដែលកំពុងបន្តដំណើរការ។ ប្រសិនបើ **មាស មុត** សម្រេចឱ្យសួរចម្លើយ តាមវិធានផ្ទៃក្នុង ៥៨ គាត់នឹងមានសិទ្ធិពិគ្រោះជាមួយមេធាវីមុនពេលសួរចម្លើយ និងមានសិទ្ធិឱ្យមេធាវីរបស់គាត់មានវត្តមាន ប្រសិនបើគាត់មិនលះបង់សិទ្ធិនោះទេ។

២១. ដោយអនុលោមតាមវិធានផ្ទៃក្នុង ៥៥(១០) និងវិធានផ្ទៃក្នុង ៥៨(៦) នៅគ្រប់ពេលក្នុងអំឡុងពេលស៊ើបសួរ **មាស មុត** មានសិទ្ធិស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬ បំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ។

២២. មុនពេលបញ្ចប់កិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេត អាចសម្រេចដាក់ **មាស មុត** ឱ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋបន្ថែមទៀតដោយផ្អែកលើការចោទប្រកាន់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឆ្នាំ ២០១៤ ប្រសិនបើ សហចៅក្រមស៊ើបអង្កេត ជឿជាក់ថា មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា គាត់អាចទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងនោះ។

ភ្នំពេញ ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥

**ចៅក្រម** Mark B. Harmon
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
International Co- Investigating Judge
Co-juge d'instruction International